ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តភ្នំពេញ**

លេខៈ ..០០៧/១៨....ក.ស.ភ.

ថ្ងៃពុធ ៩រោច ខែបុស្ស ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមករា គ.ស.២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## ការស្តុកទុកកុងតឺន័រផ្ទុកទំនិញគ្រោះថ្នាក់នៅចំណតផែកុងតឺន័រ LM១៧

**កំពង់ផែស្វយ័តភ្នំពេញ** (ក. ស. ភ.) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អតិថិជន ដែលជាក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាសុវត្ថិភាពលើការងារប្រតិបត្តិការលើកដាក់ និងរក្សាទុកទំនិញគ្រោះថ្នាក់នៅក្នុងបរិវេណចំណតផែកុងតឺន័រ LM១៧ ក. ស. ភ. បានរៀបចំទីលានសមស្របមួយដាច់ដោយឡែក ដើម្បីធ្វើការគ្រប់គ្រង និងរក្សាទុកទំនិញគ្រោះថ្នាក់ទាំងនោះ។ ដូចនេះ ដើម្បីជួយសម្រួលដល់ការអនុវត្តការងារខាងលើឲ្យមានប្រសិទ្ធភាព ក. ស. ភ. តម្រូវឲ្យលោក លោកស្រី ភាគីក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូនមេត្តាជួយផ្តល់ព័ត៌មាន ស្តីពី ទំនិញគ្រោះថ្នាក់តាមទំរង់ **IMO FAL Form 7** (ដូចបានភ្ជាប់ជូន) ឲ្យបាន ២៤ម៉ោងមុនពេលនាវាមកដល់ (សម្រាប់ការនាំចូល) និង២៤ម៉ោងមុនពេលកុងតឺន័រដឹកជញ្ជូនចូលមកដល់ទីលានរបស់ ក. ស. ភ. (សម្រាប់ការនាំចេញ) ជូនមក ក. ស. ភ. តាមរយៈអ៊ីម៉ែល "**dangerousgoods-ops@ppap.com.kh**"។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់៖

| | | |
|---|---|---|
| ១.លោក **អ៊ឹង ឆាយងួន** | ប្រធានអង្គភាពរៀបចំប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៣៩៨ |
| ២.លោក **លឹម វឌ្ឍនា** | ប្រធានអង្គភាពរៀបវេនប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៣៨៩ |
| ៣.លោក **អ៊ិង សុភ័ក្រ្ត** | អនុប្រធានអង្គភាពរៀបចំប្រតិបត្តិការ LM១៧ | លេខទូរស័ព្ទ៖ ០១០ ៨៨៨ ៦៩៧ |

ក្នុងករណីខកខានពុំបានជូនដំណឹងមក ក. ស. ភ. ជាមុននូវព័ត៌មានស្តីពីទំនិញគ្រោះថ្នាក់ នោះភាគីក្រុមហ៊ុននាវា និងក្រុមហ៊ុនដឹកជញ្ជូន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់នូវរាល់ករណីគ្រោះថ្នាក់ និងខូចខាតទាំងឡាយណាដែលបង្កដោយទំនិញនោះ។

**សេចក្តីជូនដំណឹងនេះ ចាប់អនុវត្តពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៨ តទៅ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមអតិថិជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា**

**ប្រធានអគ្គនាយក**

**ហ៊ី-ឋាវី**

**KINGDOM OF CAMBODIA**
**Nation Religion King**

**Phnom Penh Autonomous Port**
N°: .....007/18........PPAP

PHNOM PENH, Date: January 10, 2018

**Announcement**
**on**
**Containers Loaded with Dangerous Goods at Container Terminal LM17**

Phnom Penh Autonomous Port (PPAP) would like to inform all the barge operators and the shipping line companies that in order to ensure the safety of handling and storage of the dangerous-goods containers at Container Terminal LM17, PPAP has set up a separate area to store those containers. Therefore, to ensure an effective implementation, PPAP requires all barge operators and shipping line companies to provide advanced information about dangerous goods at least 24hrs before the arrival of the barge/vessel (for import) and 24hrs before the container arrives at the port (for export) in the format of **IMO FAL Form 7** (as per attachment) to PPAP via this email address **"dangerousgoods-ops@ppap.com.kh"**.

For more information, please kindly contact the following officers:

| | | | |
|---|---|---|---|
| **1.** | **Mr. Ung Chhay Ngoun** | Manager of Terminal Planning Unit LM17 | Tel: 010 444 398 |
| **2.** | **Mr. Lim Voitana** | Manager of Operation Shift Unit LM17 | Tel: 010 444 389 |
| **3.** | **Mr. Ung Sopheak** | Deputy Manager of Terminal Planning Unit LM17 | Tel: 010 444 697 |

**In the case that the barge operators or the shipping line companies fail to send prior information about the dangerous goods to PPAP as required, the barge operators or the shipping line companies shall be liable for all damages and costs caused by the said dangerous goods.**

This announcement is effective from **the 15th of January, 2018 onwards.**

Please all the valued customers be informed and cooperate effectively.

Sincerely yours,

**Bavy HEI**
**Delegate of Royal Government**
**in charge as Chairman & CEO**

# IMO DANGEROUS GOODS MANIFEST

(IMO FAL Form 7)

(As required by SOLAS 74, chapter VII, regulations 4.5 and 7-2.2, MARPOL 73/78, Annex III, regulation 4.3 and chapter 5.4, paragraph 5.4.3.1 of the IMDG Code)

Page Number

| 1.1 Name of ship | 1.2 IMO number | 1.3 Call sign | |
|---|---|---|---|
| 1.4 Voyage number | 2. Flag State of ship | 3. Port of loading | 4. Port of discharge |

| 5. Booking/ Reference Number | 6. Marks & Numbers Container Id. No(s). Vehicle Reg. No(s). | 7. Number and kind of packages | 8. Proper Shipping Name | 9. Class | 10. UN No. | 11. Packing Group | 12. Subsidiary Risk(s) | 13. Flashpoint (in °C c.c.) | 14. Marine Pollutant | 15. Mass (kg) Gross/Net | 16. EmS | 17. Stowage position on board |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

| Additional information | |
|---|---|
| 18.1 Name of master | 19.1 Shipping Agent |
| 18.2 Place and date | 19.2 Place and date |
| Signature of master | Signature of Agent |